Australian Aid PONLOK CHOMNES The Asia Foundation CDRI

២០២៥ លេខ ០២

# ការពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពី ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ សម្រាប់ សេវាទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ននៅកម្ពុជា

រៀបរៀងដោយ

អាង រស្មី អ្នកស្រាវជ្រាវ មជ្ឈមណ្ឌលធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI

មេលីតា ហ្គ្រេន នាយិការងផ្នែកស្រាវជ្រាវ វិទ្យាស្ថានសម្រាប់អនាគតប្រកបដោយចីរភាព សាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី ទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។

របៀបយោងអត្ថបទនេះ៖ Ang Raksmey and Melita Grant. 2025. *From Guidelines to Action: Strengthening Climate-Resilient Water Safety Planning for Inclusive Water, Sanitation and Hygiene Services in Cambodia*. Policy Brief 2025 No. 02. Phnom Penh: CDRI.

**ខ្លឹមសារសំខាន់ៗ**

- នៅឆ្នាំ២០២៣ ប្រជាពលរដ្ឋកម្ពុជារស់នៅទីក្រុងជាង ៩០% ទទួលបានសេវាទឹកស្អាតយ៉ាងហោចណាស់ស្តង់ដាជាមូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋនៅទីប្រជុំជនប្រមាណតែ ៥៦% ប៉ុណ្ណោះ ទទួលបានសេវាអនាម័យដែលមានការគ្រប់គ្រងដោយសុវត្ថិភាព រីឯប្រជាពលរដ្ឋនៅទីជនបទប្រហែល ១០% នៅតែអនុវត្តការបន្ទោរបង់ពាសវាលពាសកាល។ គួរឱ្យបារម្ភ ប្រជាពលរដ្ឋប្រហែល ១៥% នៅតែប្រើប្រាស់ទឹកដែលមិនបានធ្វើប្រព្រឹត្តកម្ម ឬសម្អាតត្រឹមត្រូវ។
- ការប្រែប្រួលអាកាសធាតុបានធ្វើឱ្យមានវិសមភាពកាន់តែខ្លាំង ក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យ (WASH) ព្រមទាំងធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធ និងប៉ះពាល់ដល់ក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ គ្រួសារក្រីក្រ ជនជាតិភាគតិច និងជនមានពិការភាព ជាងប្រជាពលរដ្ឋទូទៅ។
- ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ (WSP) គឺជាអភិក្រមគ្រប់គ្រងហានិភ័យជាប្រព័ន្ធមួយ ដែលអាចកំណត់ពីមុខសញ្ញាគ្រោះថ្នាក់ក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹក ហើយចាត់វិធានការបង្ការ និងនីតិវិធីត្រួតពិនិត្យ ដើម្បីធានាបាននូវទឹកបរិភោគដែលមានសុវត្ថិភាព ពីប្រភពផ្គត់ផ្គង់ទឹក ដល់អ្នកប្រើប្រាស់។
- ការដាក់ចេញនូវគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការធ្វើផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុ គឺជាជំហានដ៏សំខាន់មួយ សំដៅកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ លើសេវាទឹកស្អាត និងអនាម័យ។ ប៉ុន្តែយើងត្រូវតាមដានបន្តទៀតសិនពីប្រសិទ្ធភាពពេញលេញក្នុងការអនុវត្តគោលការណ៍ណែនាំនេះ។
- ការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុប្រកបដោយប្រសិទ្ធភាព ត្រូវប្រឈមនឹងបញ្ហាច្រើនយ៉ាង ដូចជា ការចូលរួមពីសហគមន៍ និងភាគីពាក់ព័ន្ធនៅមានកម្រិត ចំណេះដឹងផ្នែកបច្ចេកទេស និងផ្នែកភាពធន់នឹងអាកាសធាតុតិចតួច និងទិន្នន័យអាកាសធាតុនៅមូលដ្ឋានមិនគ្រប់គ្រាន់។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ទាមទារឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុ ការកសាងសមត្ថភាពប្រកបដោយបរិយាបន្ន និងអភិក្រមដែលគិតគូរពីយេនឌ័រ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានការប្រើប្រាស់សេវាទឹកស្អាត និងអនាម័យប្រកបដោយសមធម៌។
- ការបញ្ចូលការពិចារណាអំពីសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ជាប្រព័ន្ធ ទៅក្នុងគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ និងផ្តល់ការគាំទ្រដល់ក្រុមងាយរងគ្រោះ ទាំងនេះនឹងធានាបាននូវសេវាទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន សមធម៌ និងប្រសិទ្ធភាព។

## សេចក្តីផ្តើម

គ្រោះមហន្តរាយទាំងឡាយ ដែលបង្កឡើងដោយអាកាសធាតុ មានដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ និងខ្យល់ព្យុះទីហ្វុងជាដើម ធ្វើឱ្យខូចខាតដល់កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ (ឧ. សាលារៀន និងមណ្ឌលសុខភាព)។ គ្រោះមហន្តរាយទាំងនេះ បង្កផលប៉ះពាល់ដល់ផលិតភាពកសិកម្ម ជីវភាពរស់នៅ សុខភាពសាធារណៈ ការអប់រំ និងសេវាទឹកស្អាត និងអនាម័យ (UNDP 2022)។ ថ្វីដ្បិត ប្រទេសកម្ពុជាមានគោលដៅសម្រេចបាននូវការគ្របដណ្តប់នៃសេវាទឹកស្អាត និងអនាម័យជាសកលប្រកបដោយចីរភាពនៅឆ្នាំ២០២៥ (RGC 2011) ការទទួលបានសេវាទឹកស្អាត និងអនាម័យនាពេលបច្ចុប្បន្ន នៅតែមិនគ្រប់គ្រាន់។ នៅទូទាំងប្រទេស ការទទួលបានសេវាទឹកស្អាតយ៉ាងហោចស្តង់ដាជាមូលដ្ឋាន[១] គឺមានកម្រិតខ្ពស់ (៨៨,0%) ប៉ុន្តែនៅមានគម្លាតរវាងទីជនបទ និងទីក្រុង (៨៥,0% នៅតាមទីជនបទ ធៀបនឹង ៩៣,២% នៅតាមទីក្រុង រូបភាពទី១)។ ជាលទ្ធផល ប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទប្រហែល ១៥% ប្រើប្រាស់ប្រភពទឹកដែលមិនបានធ្វើប្រព្រឹត្តកម្ម។ សម្រាប់សេវាអនាម័យវិញ មានគ្រួសារជាងពាក់កណ្តាល ទទួលបានសេវាអនាម័យដែលមានការគ្រប់គ្រងដោយសុវត្ថិភាព និង ៣១,២% ទទួលបានត្រឹមស្តង់ដាជាមូលដ្ឋាន។ វិសមភាពរវាងទីជនបទ និងទីក្រុង នៅតែមានគួរឱ្យកត់សម្គាល់ ដោយសារគ្រួសារនៅតាមជនបទ ៩,៤% នៅតែបន្ទោរបង់ដោយគ្មានអនាម័យ (ពាសវាលពាសកាល) បើធៀបនឹងគ្រួសារនៅតំបន់ទីក្រុង មានតែ ២,៥% ប៉ុណ្ណោះ។ គេរំពឹងថា ការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យវិសមភាពដែលមានស្រាប់ កើនឡើងកាន់តែខ្លាំង ដោយសារហានិភ័យពីកង្វះទឹក និងការចម្លងរោគដែលច្រើនតែកើតមានចំពោះកុមារ មនុស្សចាស់ ស្ត្រី និងអ្នករស់នៅក្នុងការតាំងទីលំនៅមិនច្បាស់លាស់ ជាងប្រជាពលរដ្ឋទូទៅ (UNICEF 2024)។

ដើម្បីគ្រប់គ្រងសុខភាពសាធារណៈ និងហានិភ័យដែលបណ្តាលមកពីអាកាសធាតុ នៅក្នុងវិស័យទឹកស្អាត និងអនាម័យ ឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលការណ៍ណែនាំស្តីពី ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុកាលពីឆ្នាំ២០២៣កន្លងទៅ។ ក្រសួងអភិវឌ្ឍន៍ជនបទ (ក.អ.ជ.) និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) បានបង្កើតគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ដើម្បីពង្រឹងប្រព័ន្ធផ្គត់ផ្គង់ទឹករៀងៗខ្លួន។ ក្រសួង អ.ជ. បានផ្តោតលើការផ្គត់ផ្គង់ទឹកតាមទីជនបទ ដោយដាក់បញ្ចូលការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងភាពធន់នឹងគ្រោះមហន្តរាយនៅថ្នាក់ឃុំ ព្រមទាំងសង្កត់ធ្ងន់លើការការពារការបំពុលចាប់ពីប្រភពទឹក រហូតដល់ការប្រើប្រាស់ ចំណែកឯក្រសួង ឧ.វ.ប.ន. បានផ្តោតលើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន (PWOs) ដោយមានយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ដែលធានាបាននូវការផ្គត់ផ្គង់ទឹកដោយសុវត្ថិភាពសម្រាប់សហគមន៍ (MISTI 2023; MRD 2023)។ គោលការណ៍ណែនាំនេះបង្ហាញអំពីដំណើរការជា ៦ ជំហាន ក្នុងការធ្វើផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ រួមមាន ការបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ការវាយតម្លៃហានិភ័យក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹក ការអនុវត្តផែនការសកម្មភាព ការត្រួតពិនិត្យនិងវាយតម្លៃ និងការត្រួតពិនិត្យឡើងវិញតាមកាលកំណត់ ដើម្បីកែលម្អដំណើរការធ្វើផែនការ និងការផ្តល់សេវាកម្ម (រូបភាពទី២)។

ទោះបីជាផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ត្រូវបានអនុវត្តយូរមកហើយនៅក្នុងប្រទេសជាង ៩០ ក៏ដោយ (String and Lantagne 2016) ប៉ុន្តែការដាក់ចេញគោលការណ៍ណែនាំនាពេលថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងការផ្តល់ហិរញ្ញវត្ថុដែលមានកម្រិតសម្រាប់ការអនុវត្ត បានធ្វើឱ្យមានមន្ទិលសង្ស័យអំពីប្រសិទ្ធភាពរបស់វា សម្រាប់ការលើកកម្ពស់សេវាទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ និងប្រកបដោយបរិយាបន្ន។ ដើម្បីយល់កាន់តែច្បាស់អំពី ការអនុវត្តគោលការណ៍ណែនាំរបស់អង្គការសង្គមស៊ីវិល វិទ្យាស្ថាន CDRI ដោយសហការជាមួយដៃគូមកពីប្រទេសអូស្ត្រាលី និងកម្ពុជា[២] បានបង្កើតគម្រោងស្រាវជ្រាវមួយ ក្នុងគោលបំណងគាំទ្រដល់អង្គការសង្គមស៊ីវិល សមាគមនានាដែលធ្វើការក្នុងវិស័យទឹកស្អាត និងអនាម័យ និងតួអង្គរដ្ឋាភិបាល ក្នុងការទទួលយក និងអនុវត្តគោលការណ៍ណែនាំទាំងនេះ។

ការសិក្សានេះ ប្រើប្រាស់ការស្រាវជ្រាវតាមបែបប្រតិបត្តិ និងការចូលរួម ដើម្បីឈ្វេងយល់ពីចំណេះដឹងរបស់ភាគីពាក់ព័ន្ធ និងការអនុវត្តគោលការណ៍ណែនាំស្តីពី ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ និងកំណត់កត្តាលើកទឹកចិត្តសម្រាប់ការទទួលយកគោលការណ៍ណែនាំនេះ។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈការធ្វើវិរេចនាឯកសារមានស្រាប់ ការសង្កេតតាមរយៈការចុះសិក្សានៅមូលដ្ឋាន ការសម្ភាសជនបង្គោល (KIIs) និងការពិភាក្សាក្រុមគោលដៅ (FGDs) ជាមួយភាគីពាក់ព័ន្ធនឹងវិស័យទឹកស្អាត និងអនាម័យ សរុបចំនួន ៥៥នាក់ រួមមានមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្រុមប្រឹក្សាឃុំសង្កាត់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងតំណាងសហគមន៍។ ការសិក្សានេះបានជ្រើសរើសអ្នកចូលរួម

.......................................

១ ដោយសារអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០២៣ ខ្វះទិន្នន័យអំពីគុណភាពទឹក ដូចនេះ យើងមិនអាចបែងចែករវាងសេវាទឹកស្អាតដែលមានការគ្រប់គ្រងដោយសុវត្ថិភាព និងសេវាទឹកស្អាតស្តងដាជាមូលដ្ឋានបានទេ។ អាស្រ័យហេតុនេះ ស្តង់ដាសេវាទឹកស្អាតទាំងពីរកម្រិតនេះ ត្រូវបានដាក់ជាប្រភេទតែមួយក្រោមឃ្លាថា “យ៉ាងហោចណាស់ សេវាស្តង់ដាជាមូលដ្ឋាន” ក្នុងរូបភាពទី១។

២ ការសិក្សានេះ មានការចូលរួមពីដៃគូមកពីប្រទេសកម្ពុជា និងអូស្ត្រាលី៖ វិទ្យាស្ថាន CDRI និងវិទ្យាស្ថានសម្រាប់អនាគតប្រកបដោយចីរភាពនៃសាកលវិទ្យាល័យបច្ចេកវិទ្យាស៊ីដនី (UTS-ISF) ជាដៃគូដឹកនាំការស្រាវជ្រាវ និងអង្គការលោកខាងលិចជួបខាងកើត (EMW) អង្គការវ៉តធីអេត កម្ពុជា (WaterAid Cambodia) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) ជាដៃគូអនុវត្តន៍គម្រោង។

រូបភាពទី១៖ លទ្ធភាពទទួលបានសេវា ក) ទឹកស្អាត និង ខ) អនាម័យនៅកម្ពុជា (២០២៣)




ប្រភព៖ អ្នកនិពន្ធរៀបរៀងដោយផ្អែកលើទិន្នន័យពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០២៣

រូបភាពទី២៖ គោលការណ៍ណែនាំទាំង ៦ ជំហានសម្រាប់ការធ្វើផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ




ប្រភព៖ ដកស្រង់ពីគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុរបស់ក្រសួង ឧ.វ.ប.ន. (២០២៣)

មកពីថ្នាក់ជាតិ និងខេត្តចំនួនពីរ (ពោធិ៍សាត់ និងកំពង់ឆ្នាំង) ជាខេត្តដែលបានចុះធ្វើការស្រាវជ្រាវ។ ផ្អែកលើការវិភាគទៅលើទិន្នន័យទាំងនេះ សង្ខេបគោលនយោបាយនេះបានសិក្សាពិនិត្យការអនុវត្តគោលការណ៍ណែនាំស្តីពី ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុនាពេលបច្ចុប្បន្ន និងឈ្វេងយល់ពីកត្តាលើកទឹកចិត្តនានា ដើម្បីកែលម្អការទទួលយកការអនុវត្តគោលការណ៍ទាំងនេះ។ មិនតែប៉ុណ្ណោះ សង្ខេបគោលនយោបាយនេះ បានបញ្ចូលលទ្ធផលសំខាន់ៗពីកិច្ចសន្ទនាគោលនយោបាយថ្នាក់ក្រោមជាតិ ដោយមានការអញ្ជើញចូលរួមពីភាគីពាក់ព័ន្ធនឹងវិស័យទឹកស្អាត និងអនាម័យ ដែលប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៥ កន្លងទៅ។

## លទ្ធផលសំខាន់ៗ

### *ភាគីពាក់ព័ន្ធនឹងវិស័យទឹកស្អាត និងអនាម័យសំខាន់ៗ៖ តើភាគីពាក់ព័ន្ធទាំងនេះ ជំរុញការអភិវឌ្ឍ និងការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុយ៉ាងណាខ្លះ?*

#### *តួនាទីរបស់រាជរដ្ឋាភិបាល*

ក្រសួង អ.ជ. និងក្រសួង ឧ.វ.ប.ន. ជាតួអង្គរដ្ឋាភិបាលក្នុងវិស័យទឹកស្អាត និងអនាម័យនៅកម្ពុជា ដែលក្រសួងនីមួយៗមានតួនាទីផ្សេងៗគ្នា ប៉ុន្តែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក នៅក្នុងផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។ ក្រសួងទាំងពីរនេះ បានផ្តល់ការគាំទ្រចំពោះគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុកម្ពុជា។ ក្រសួង អ.ជ. ធ្វើការផ្តោតលើតំបន់ជនបទ ដោយគ្រប់គ្រងទាំងប្រព័ន្ធទឹកស្អាតគ្មានបំពង់ (ឧ. អណ្តូង និងស្រះ) និងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ និងបរិក្ខារអនាម័យ។ ទន្ទឹមនឹងនេះ ក្រសួង ឧ.វ.ប.ន. មានតួនាទីគ្រប់គ្រង និងគាំទ្រប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅតាមទីក្រុង និងតំបន់ជុំវិញទីក្រុង ដោយជំរុញការអនុវត្តបទដ្ឋានគុណភាពទឹក និងលើកកម្ពស់នវានុវត្តន៍បច្ចេកវិទ្យា។ លើសពីនេះ ក្រសួងសំខាន់ៗផ្សេងទៀត ក៏បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងគុណភាពផ្គត់ផ្គង់ទឹកស្អាត និងអនាម័យផងដែរ។ ក្នុងនោះ ក្រសួងសាធារណការ និងដឹកជញ្ជូន មានតួនាទីត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធទឹកកខ្វក់ និងសំណល់ភក់បង្គន់ ក្រសួងបរិស្ថាន មានតួនាទីជំរុញការអនុវត្តបទដ្ឋានទឹកកខ្វក់ឧស្សាហកម្ម ហើយក្រសួងធនធានទឹក និងឧតុនិយម មានតួនាទីគ្រប់គ្រងធនធានទឹក និងគោលនយោបាយអាកាសធាតុជាតិ។ ស្ថាប័នជាតិទាំងនេះ ត្រូវបានគាំទ្រដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមសហការជាមួយ អង្គការសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគោលនយោបាយ ផ្តល់ការបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសេវាទឹកស្អាត និងអនាម័យ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

#### *តួនាទីរបស់សង្គមស៊ីវិល*

អង្គការសង្គមស៊ីវិល មានតួនាទីសំខាន់ចំពោះផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុនៅកម្ពុជា ដោយអនុវត្តគំនិតផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន និងការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរគោលនយោបាយ។ សង្គមស៊ីវិលធ្វើការដោយផ្ទាល់ជាមួយសហគមន៍ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ការបណ្តុះបណ្តាលអំពីទឹកស្អាត និងអនាម័យ កសាងហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងលើកកម្ពស់ដំណើរការធ្វើផែនការប្រកបដោយបរិយាបន្ន ដោយមានការចូលរួមពីក្រុមងាយរងគ្រោះ។ សង្គមស៊ីវិលក៏បានផ្តល់ ឬឧបត្ថម្ភជាធនធាននានា ដូចជា បង្គន់អនាម័យ និងឧបករណ៍ចម្រោះទឹកជាដើមផងដែរ។ នៅកម្រិតគោលនយោបាយ សង្គមស៊ីវិលសហការជាមួយក្រសួងមន្ទីរនានា ដើម្បីដាក់បញ្ចូលការវាយតម្លៃហានិភ័យអាកាសធាតុ ទៅក្នុងគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុជាតិ និងគាំទ្រប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ សង្គមស៊ីវិលជួយពង្រឹងសមត្ថភាពនៅមូលដ្ឋានតាមរយៈការបណ្តុះបណ្តាលអាជ្ញាធរថ្នាក់ក្រោមជាតិ និងសមាជិកសហគមន៍។ អង្គការសង្គមស៊ីវិលដែលធ្វើការផ្តោតលើវិស័យទឹកស្អាត និងអនាម័យ មានវិសាលភាពតួនាទីខុសប្លែកគ្នា ប៉ុន្តែអង្គការសង្គមស៊ីវិលទាំងនេះ មានកិច្ចខិតខំប្រឹងប្រែងរួម ដើម្បីជំរុញការគ្រប់គ្រងធនធានទឹកដែលធន់នឹងអាកាសធាតុនៅកម្ពុជាដែរ។ តាមរយៈការកសាងសមត្ថភាពនៅមូលដ្ឋាន សង្គមស៊ីវិលធានាថា ភាគីពាក់ព័ន្ធនានាមានជំនាញ និងចំណេះដឹងក្នុងការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ខណៈត្រូវធ្វើឱ្យមានតុល្យភាពរវាងតម្រូវការនៅមូលដ្ឋាន ជំនាញបច្ចេកទេស និងក្របខ័ណ្ឌគោលនយោបាយ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ អង្គការសង្គមស៊ីវិលបានជួយដោះស្រាយបញ្ហាខ្វះចន្លោះមួយចំនួន ក្នុងការអនុវត្តគោលនយោបាយ ដោយជំរុញឱ្យមានដំណោះស្រាយ ចំពោះបញ្ហាប្រឈមផ្នែកសន្តិសុខទឹកនៅកម្ពុជា ជាដំណោះស្រាយដែលមានការចូលរួមពីភាគីពាក់ព័ន្ធ និងមានភាពធន់នឹងអាកាសធាតុ។

### *ការអភិវឌ្ឍ ការទទួលយក និងការអនុវត្តគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ*

អង្គការសង្គមស៊ីវិល និងសមាគមនានា បានបញ្ចូលគោលការណ៍ណែនាំស្តីពី ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុរបស់ក្រសួង អ.ជ. និង ក្រសួង ឧ.វ.ប.ន. ទៅក្នុងឯកសារសម្រាប់កម្មវិធីកសាងសមត្ថភាព និងការបណ្តុះបណ្តាលសម្រាប់រដ្ឋបាលមូលដ្ឋាន សហគមន៍ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន សំដៅបង្កើនការយល់ដឹងអំពីភាពធន់នឹងអាកាសធាតុ។ អង្គការសង្គមស៊ីវិល និងសមាគមទាំងនេះក៏បានសម្រួលឯកសារសម្រាប់បណ្តុះបណ្តាល ឱ្យស្របនឹងបរិបទរបស់មូលដ្ឋាន ដោយប្រើក្របខ័ណ្ឌផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុរបស់អង្គការសុខភាពពិភពលោក និង

គោលការណ៍ណែនាំស្តីពី វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់របស់ក្រសួង ឧ.វ.ប.ន. ដើម្បីរៀបចំឯកសារសម្រាប់បណ្តុះបណ្តាល។ គោលការណ៍ណែនាំទាំងនេះ គឺជាឯកសារយោងដ៏សំខាន់ ដែលមានវិធីសាស្រ្តជារចនាសម្ព័ន្ធ ក្នុងការវាយតម្លៃសមត្ថភាពនៅមូលដ្ឋាន ដែលអង្គការសង្គមស៊ីវិលយកទៅប្រើបាន សំដៅបង្កើនភាពធន់នៃប្រព័ន្ធទឹកស្អាត តាមរយៈការធ្វើផែនទីប្រព័ន្ធផ្គត់ផ្គង់ទឹក និងប្រភពទឹក ការវាយតម្លៃហានិភ័យ និងការធ្វើផែនការសកម្មភាព។ ក្រុមផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ត្រូវបានបង្កើតឡើងដោយមានសមាជិកជាមេភូមិ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ អ្នកស្ម័គ្រចិត្តសហគមន៍ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អ្នកផ្តល់សេវាអនាម័យ និងមន្រ្តីរាជការខេត្ត/ស្រុក។ ក្រុមការងារទាំងនេះបានទទួលការបណ្តុះបណ្តាលអំពី គោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ដែលមាន ៦ ជំហាន (រូបភាពទី២) ដោយផ្តោតលើការវាយតម្លៃហានិភ័យទាក់ទងនឹងបរិស្ថាននិងអាកាសធាតុ ចំពោះប្រភពទឹក និងការកសាងផែនការសកម្មភាពដើម្បីធ្វើការកែលម្អបន្ថែម។ ទោះបីជាអង្គការសង្គមស៊ីវិលភាគច្រើន មិនបានចូលរួមដោយផ្ទាល់ ក្នុងការបង្កើតគោលការណ៍ណែនាំក៏ដោយ ប៉ុន្តែអង្គការមួយចំនួនបានផ្តល់ជាធាតុចូលនៅក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ ដែលរៀបចំដោយក្រសួង អ.ជ. ឬ ក្រសួង ឧ.វ.ប.ន. និងគាំទ្រដោយអង្គការយូនីសេហ្វ។

### *គន្លឹះជោគជ័យនៃផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ៖ តើអ្វីខ្លះជាកត្តាជំរុញការទទួលយក និងអ្វីខ្លះជាឧបសគ្គ?*

### *លទ្ធផលវិជ្ជមានពីការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ*

ការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ បានធ្វើឱ្យលទ្ធភាពទទួលបានទឹកស្អាតប្រសើរឡើង ជាពិសេសតាមរយៈការដំឡើងបំពង់បណ្តាញទឹក និងឧបករណ៍ចម្រោះទឹក ក៏ដូចជាការធ្វើវិសិដ្ឋកម្មបច្ចេកទេស ដែលអាចឱ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ពង្រឹងការគ្រប់គ្រងគុណភាពទឹក។ ខណៈដែលភស្តុតាងផ្ទាល់ (ឧ. ការធ្វើតេស្តពីគុណភាពទឹក) នៅមិនទាន់ឃើញមានធ្វើនៅឡើយ វិធានការទាំងនេះ អាចនាំមកនូវលទ្ធផលវិជ្ជមាន សម្រាប់សុខភាពប្រជាពលរដ្ឋនៅក្នុងសហគមន៍។ ម្យ៉ាងទៀត ដំណើរការបណ្តុះបណ្តាល និងការធ្វើផែនការ បានបង្កើនការយល់ដឹងអំពីហានិភ័យអាកាសធាតុ (ឧ. គ្រោះរាំងស្ងួត និងទឹកជំនន់) ព្រមទាំងបង្រៀនប្រជាពលរដ្ឋក្នុងសហគមន៍ ឱ្យយល់ដឹងពីយុទ្ធសាស្រ្តកាត់បន្ថយហានិភ័យដូចជា ការស្តុកទឹកទុក ការប្រើប្រាស់ទឹកដោយសន្សំសំចៃ និងផែនការប្រើប្រាស់ទឹក ដែលទាំងនេះជួយពង្រឹងភាពធន់របស់សហគមន៍ ទៅនឹងការប្រែប្រួលអាកាសធាតុ។ លើសពីនេះ ការចំណាយរបស់គ្រួសារក្រីក្របានថយចុះ ដោយសារមានម៉ាស៊ីនឬធុងចម្រោះទឹក (ចម្រោះទឹកដោយប្រើខ្សាច់)។ វិធានការនេះបានកាត់បន្ថយភាពចាំបាច់ក្នុងការទិញទឹកដប និងបានលើកកម្ពស់អនាម័យ តាមរយៈការសង់បង្គន់អនាម័យថ្មីជាដើម។ ដំណើរការបណ្តុះបណ្តាល និងធ្វើផែនការ ក៏បានបង្ហាញពីសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ក្នុងការសហការ និងផ្តល់អាទិភាពដល់សកម្មភាពរួមគ្នាផងដែរ។

### *បញ្ហាប្រឈម និងការលើកទឹកចិត្ត ចំពោះការអភិវឌ្ឍ និងអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ*

ការអនុវត្ត ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុប្រឈមមុខនឹងបញ្ហានានាជាច្រើន ដោយសារការចូលរួមរបស់សហគមន៍មានកម្រិតទាបនៅឡើយ កង្វះចំណេះដឹងអំពីទំនាក់ទំនង រវាងការប្រែប្រួលអាកាសធាតុ និងសេវាទឹកស្អាតនិងអនាម័យ ទិន្នន័យអាកាសធាតុនៅមូលដ្ឋានមានកម្រិត បញ្ហាប្រឈមផ្នែកភស្តុភារកម្ម និងហិរញ្ញប្បទានរបស់រដ្ឋាភិបាលមិនទាន់គ្រប់គ្រាន់។ ប្រជាពលរដ្ឋនៅមូលដ្ឋានជាច្រើន មិនបានចូលរួមការប្រជុំ និងវគ្គបណ្តុះបណ្តាល ដោយសារជាប់រវល់ធ្វើការងារ ឬកង្វះការយល់ដឹងអំពីការគ្រប់គ្រងទឹក និងផលជះនៃគម្រោងទឹកស្អាតនានា ដែលទាមទារឱ្យថ្នាក់ដឹកនាំនៅមូលដ្ឋានទៅអញ្ជើញពួកគាត់ឱ្យចូលរួមដោយផ្ទាល់។ ការយល់ខុសមួយចំនួន ដូចជា ការមិនទុកចិត្តលើប្រព័ន្ធបំពង់បណ្តាញទឹកស្អាតជាដើម បានកាត់បន្ថយការចូលរួមមួយកម្រិតបន្ថែមទៀត។ លើសពីនេះទៀត សហគមន៍ខ្វះចំណេះដឹងអំពីភាពធន់នឹងអាកាសធាតុ ដែលមួយផ្នែកដោយសារតែទិន្នន័យ និងព័ត៌មាននៅមូលដ្ឋានមិនគ្រប់គ្រាប់។ លទ្ធភាពទទួលបានវគ្គបណ្តុះបណ្តាល គឺជាឧបសគ្គមួយទៀត៖ ស្ត្រីមួយចំនួនមិនអាចចូលរៀនវគ្គបណ្តុះបណ្តាលបានទេ ដោយសារមានកាតព្វកិច្ចការងារផ្ទះ ចំណែកមនុស្សចាស់និងជនមានពិការភាពវិញ មានបញ្ហាក្នុងការធ្វើដំណើរ ទៅកាន់ទីតាំងបណ្តុះបណ្តាល។ ម្យ៉ាងវិញទៀត ភាសាបច្ចេកទេសនៅក្នុងឯកសារបណ្តុះបណ្តាល ក៏បានធ្វើឱ្យសិក្ខាកាមមួយចំនួនពិបាកយល់ផងដែរ។

ដើម្បីធ្វើឱ្យការអភិវឌ្ឍ និងការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុប្រសើរឡើង ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលចាំបាច់ត្រូវធ្វើជាប្រចាំ សម្រាប់ក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ និងប្រជាពលរដ្ឋក្នុងសហគមន៍ មិនមែនធ្វើតែម្តងហើយក៏ចប់ត្រឹមហ្នឹងនោះទេ។ ការរៀបចំចងក្រងឯកសារសម្រាប់បណ្តុះបណ្តាលរួមគ្នា ដោយប្រើភាសាសាមញ្ញងាយយល់ មានរំលេចដោយរូបភាព និងមានវគ្គបណ្តុះបណ្តាលខ្លីតែញឹកញាប់ ទាំងនេះនឹងជួយឱ្យសហគមន៍អាចធ្វើការវាយតម្លៃហានិភ័យ និងបង្កើតផែនការសកម្មភាពដើម្បីឆ្លើយតបនឹងហានិភ័យចំពោះមុខប្រកបដោយបរិយាបន្ន។ ការផ្តល់ការឧបត្ថម្ភថវិកាសម្រាប់មធ្យោបាយធ្វើដំណើរ និងអាហារ ក៏ដូចជា ការឧបត្ថម្ភថវិកាចំពោះសកម្មភាពទាំងឡាយណាដែលកំណត់ថា ជាការជួយកែលម្អគ្រឿងបរិក្ខារទឹកស្អាតនិងអនាម័យ និងធ្វើឱ្យវាកាន់តែមានភាពធន់នឹងអាកាសធាតុ

ទាំងនេះត្រូវការជាចាំបាច់ ដើម្បីកែលម្អដំណើរការផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។ ការគាំទ្របន្ថែមដល់ក្រុមងាយរងគ្រោះ គឺជាការចាំបាច់ ជាពិសេសជនមានពិការភាពដែលពិបាកក្នុងការធ្វើដំណើរ។ ការប្រជុំ ឬបណ្តុះបណ្តាលនាពេលអនាគត គួរតែបញ្ចូលអភិក្រមដែលគិតគូរពីយេនឌ័រ ឯកសារសម្រាប់បណ្តុះបណ្តាលសាមញ្ញ និងអភិក្រមសហការប្រកបដោយបរិយាបន្ន។ ការពង្រឹងទិន្នន័យ និងការចែករំលែកព័ត៌មានជាពិសេសទាក់ទងនឹងហានិភ័យអាកាសធាតុ និងដំណើរការធ្វើផែនការរួមគ្នាក្នុងចំណោមអាជ្ញាធរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ក៏មានសារៈសំខាន់ផងដែរ។

### ការដោះស្រាយគម្លាត៖ តើគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ជំរុញសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមយ៉ាងដូចម្តេច?

### ការអភិវឌ្ឍ និងការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុប្រកបដោយបរិយាបន្ន

ដើម្បីធានាបាននូវសមធម៌ និងប្រសិទ្ធភាពនៃផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ចាំបាច់ត្រូវបញ្ចូលសំឡេងស្ត្រី កុមារ គ្រួសារក្រីក្រ និងជនមានពិការភាព កាន់តែច្រើនទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តគម្រោង។ ការអនុវត្តនេះតម្រូវឱ្យបញ្ចូលតំណាងរបស់ពួកគេទៅក្នុង ក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យ ក៏ដូចជា កសាងហេដ្ឋារចនាសម្ព័ន្ធដែលអាចប្រើប្រាស់បានគ្រប់គ្នា (ឧ. ផ្លូវរទេះរុញ) ដែលបានរចនាឡើងសម្រាប់ជនងាយរងគ្រោះ រួមទាំង ស្ត្រីមានផ្ទៃពោះ ជនមានពិការភាព ឬមនុស្សចាស់។ ការចូលរួមរបស់ស្ត្រី មានសារៈសំខាន់ណាស់ ដោយសារការយល់ដឹងរបស់ស្ត្រី ចំពោះការគ្រប់គ្រងទឹកក្នុងគ្រួសារ បង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគម្រោង ចំណែកឯការចូលរួមរបស់កុមារ ជាពិសេសតាមរយៈការអប់រំអនាម័យនៅតាមសាលារៀន ជួយលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថសម្រាប់រយៈពេលវែង។

ថ្វីដ្បិតការអភិវឌ្ឍ និងការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ បានដោះស្រាយបញ្ហាសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម បានមួយកម្រិត បញ្ហាប្រឈមនៅតែមាន ជាពិសេសសម្រាប់អ្នកដឹកនាំជាស្ត្រី ដែលទទួលការរើសអើងផ្នែកយេនឌ័រ មានការលំបាកក្នុងការរក្សាតុល្យភាពរវាងជីវិតនិងការងារ បារម្ភពីសុវត្ថិភាព និងមានឱកាសអភិវឌ្ឍន៍ជំនាញតិចតួច។ ដើម្បីផ្លាស់ប្តូរបទដ្ឋានសង្គមទាំងនេះ និងលើកកម្ពស់សមភាពសង្គម ទាមទារឱ្យមានការយល់ដឹងទូលំទូលាយក្នុងចំណោមប្រជាពលរដ្ឋក្នុងសហគមន៍។ ក្នុងដំណើរការផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ មានជាច្រើនដំណាក់កាល ដែលអាចរចនារៀបចំឡើងឱ្យមានបរិយាបន្នដោយចាប់ផ្តើមពីការបង្កើត គណៈកម្មាធិការផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ រហូតដល់ការវាយតម្លៃហានិភ័យ និងការបង្កើតនិងអនុវត្តផែនការសកម្មភាព ដែលតម្រូវឱ្យមានធាតុចូល និងមតិចម្រុះ។ ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារ ប្រឈមនឹងឧបសគ្គជាប្រព័ន្ធ ក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យ ដោយសារតែពួកគេមានបន្ទុកធំពីរយ៉ាងគឺ ការថែទាំកូន និងការរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ អន្តរាគមន៍គោលដៅ គឺជាការចាំបាច់ ដើម្បីធានាបាននូវលទ្ធភាពទទួលបានសេវាដោយសមធម៌ រួមទាំងការផ្តល់ឧបត្ថម្ភធន ការទទួលបានការថែទាំសុខភាពល្អ និងការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ ការអនុវត្តកិច្ចអន្តរាគមន៍ទាំងនេះឱ្យមានប្រសិទ្ធភាព ទាមទារឱ្យមានកិច្ចសហការស្អិតរមួត ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងអង្គការសង្គមស៊ីវិល ដែលអំណោយផលដល់ការគាំទ្រគោលដៅ និងការធ្វើឱ្យលទ្ធភាពទទួលបានសេវាទឹកស្អាត និងអនាម័យប្រសើរឡើងនៅក្នុងតំបន់ដែលខ្វះខាត។

### ការពិនិត្យសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម នៅក្នុងគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុនៅកម្ពុជា

ការពិនិត្យគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុរបស់ក្រសួង ឧ.រ.ប.ន. និងក្រសួង អ.ជ. បានបង្ហាញពីភាពខ្វះចន្លោះមួយចំនួន ក្នុងការបញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមជាប្រព័ន្ធ និងបង្ហាញពីឱកាសសម្រាប់បង្កើនការយកចិត្តទុកដាក់ និងការណែនាំស្តីពីបរិយាបន្ននៅក្នុងដំណើរការផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។ ខណៈដែលគោលការណ៍ណែនាំរបស់ក្រសួង អ.ជ. លើកកម្ពស់តុល្យភាពយេនឌ័រ និងបញ្ចូលគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គ.ក.ន.ក.) នៅក្នុងក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ គោលការណ៍ណែនាំនេះគួរតែពង្រឹងដំណើរការប្រមូលធាតុចូលពីសហគមន៍ ដើម្បីធ្វើឱ្យការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមកាន់តែប្រសើរឡើង។ ផ្ទុយទៅវិញ គោលការណ៍ណែនាំរបស់ក្រសួង ឧ.រ.ប.ន. ដែលផ្តោតលើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ខ្វះវិធានការច្បាស់លាស់ចំពោះបរិយាបន្នយេនឌ័រ និងតួនាទីរបស់សហគមន៍។ ដើម្បីបង្កើនប្រសិទ្ធភាពផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ គោលការណ៍ណែនាំទាំងពីរ គួរតែពង្រឹងការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម តាមរយៈការធ្វើសេចក្តីសម្រេចចិត្តដោយបរិយាបន្ន ការបណ្តុះបណ្តាលគោលដៅសម្រាប់ក្រុមងាយរងគ្រោះ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលអាចប្រើប្រាស់បានគ្រប់គ្នា។ គោលការណ៍ណែនាំទាំងពីរ អាចបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ដើម្បីដោះស្រាយបញ្ហាក្នុងការបញ្ជ្រាប

សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម រួមជាមួយនឹងគោលការណ៍ណែនាំផ្សេងទៀត ដូចជា គោលការណ៍ណែនាំដែលដាក់ចេញដោយអង្គការសុខភាពពិភពលោក (WHO 2019)។

### *ខ្លឹមសារពីកិច្ចសន្ទនាគោលនយោបាយ៖ ការពង្រឹងសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុ និងប្រកបដោយបរិយាបន្ននៅសហគមន៍មូលដ្ឋាន*

កិច្ចសន្ទនាគោលនយោបាយថ្នាក់ក្រោមជាតិ បានកំណត់នូវវិធានការសំខាន់ៗ ដើម្បីលើកកម្ពស់សេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុ និងប្រកបដោយបរិយាបន្ននៅក្នុងសហគមន៍មូលដ្ឋាន។ វិធានការទាំងនេះ រួមមាន ការផ្ដល់ជំនួយជាថវិកាសម្រាប់ក្រុមងាយរងគ្រោះ ដូចជា ការផ្ដល់ឧបត្ថម្ភធនលើការដំឡើងផុងចម្រោះទឹកជូនគ្រួសារក្រីក្រ និងការផ្ដល់បរិក្ខារអនាម័យដោយឥតគិតថ្លៃនៅក្នុងសហគមន៍ដាច់ស្រយាល ដែលរងផលប៉ះពាល់ពីអាកាសធាតុ។ ការដាក់បញ្ចូលផែនការគម្រោងទឹកស្អាត និងអនាម័យ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ អាចធានាបានថា ឃុំសង្កាត់នឹងដឹកនាំក្នុងការបែងចែកថវិកាសម្រាប់អនុវត្តន៍គម្រោងទឹកស្អាត និងអនាម័យ។ ការផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេស ដល់ក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសហគមន៍ ជាពិសេសក្នុងការវាយតម្លៃហានិភ័យអាកាសធាតុ និងដំណើរការធ្វើផែនការដោយបរិយាបន្ន ទាំងនេះនឹងជួយដោះស្រាយបញ្ហាប្រឈមចំពោះមុខនានាបាន។ យុទ្ធនាការផ្សព្វផ្សាយដើម្បីផ្លាស់ប្ដូរឥរិយាបថទឹងជំរុញឱ្យមានការចូលរួមពីសហគមន៍ រីឯការពង្រឹងកិច្ចសហការពីពហុភាគីពាក់ព័ន្ធ មានសារៈសំខាន់ណាស់ ក្នុងការដោះស្រាយបញ្ហាផ្នែកបច្ចេកទេស និងថវិកា។

### អនុសាសន៍គោលនយោបាយ

ការដាក់ចេញនូវគោលការណ៍ណែនាំស្ដីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុនៅកម្ពុជា គឺជាជំហានដ៏សំខាន់មួយ ឆ្ពោះទៅរកសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុ ទោះបីជាប្រសិទ្ធភាពពេញលេញនៃការអនុវត្តគោលការណ៍ណែនាំនេះ ត្រូវការការតាមដាន និងវាយតម្លៃបន្តទៀតសិនក៏ដោយ។ ការយល់ដឹងអំពីបញ្ហាប្រឈម និងការលើកទឹកចិត្តនៅក្នុងដំណើរការផែនការសុវត្ថិភាពទឹក គឺមានសារៈសំខាន់ណាស់ សម្រាប់ជំរុញការទទួលយក និងការធានាបានចីរភាពយូរអង្វែង។ ការសិក្សានេះ សូមស្នើអនុសាសន៍គន្លឹះមួយចំនួន ដើម្បីពង្រឹងការអនុវត្តផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ដែលតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួម ក្នុងចំណោមភាគីពាក់ព័ន្ធនឹងវិស័យទឹកស្អាត និងអនាម័យទាំងអស់។

- **ការលើកកម្ពស់ ការចូលរួមពីសហគមន៍ប្រកបដោយបរិយាបន្ន៖** វាមានភាពចាំបាច់ណាស់ក្នុងការសម្រួលគោលការណ៍ណែនាំស្ដីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ អនុលោមទៅតាមបរិបទនៅមូលដ្ឋាន ជាពិសេសនៅក្នុងសហគមន៍ជនបទ ដែលមានបញ្ហាប្រឈមនានា ដូចជា ធនធានមានកំណត់ ការយល់ដឹងទាបអំពីហានិភ័យក្នុងសេវាទឹកស្អាត និងអនាម័យ និងអាទិភាពច្រើនមុខនៅក្នុងជីវភាពរស់នៅដែលប្រទាញប្រទង់គ្នា។ ដើម្បីលើកទឹកចិត្តឱ្យសហគមន៍ចូលរួមសកម្ម ក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ គួរតែកំណត់ឱ្យបានច្បាស់លាស់នូវតួនាទីរបស់អ្នកតំណាងក្រុមងាយរងគ្រោះ ដូចជា ជនមានពិការភាព និងមនុស្សចាស់ជាដើម។
- **ការកសាងសមត្ថភាព និងការបណ្ដុះបណ្ដាល៖** ផ្ដល់កម្មវិធីកសាងសមត្ថភាព និងការបណ្ដុះបណ្ដាលជាប្រចាំដល់ក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ អំពីគោលការណ៍ណែនាំ ជាពិសេសការវាយតម្លៃហានិភ័យអាកាសធាតុ និងបរិស្ថាន។ គាំទ្រក្រុមប្រឹក្សាឃុំ ក្នុងការសម្រួលគោលការណ៍ណែនាំ អនុលោមទៅតាមតម្រូវការមូលដ្ឋាន ហើយរក្សាបាននូវភាពស្របគ្នាទៅនឹងគោលដៅជាតិ។ ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលកាន់តែប្រសើរឡើងសម្រាប់គ្រប់គ្នា ភាគីពាក់ព័ន្ធគួរពិចារណាចុះទៅដល់ផ្ទះប្រជាពលរដ្ឋតែម្ដង និងប្រើប្រាស់រូបភាពជាជំនួយក្នុងវគ្គបណ្ដុះបណ្ដាល។ ការរៀបចំវគ្គបណ្ដុះបណ្ដាលទៅដល់មូលដ្ឋាន នៅទីប្រជុំជនភូមិ នឹងកាត់បន្ថយបន្ទុកធ្វើដំណើរជាពិសេសសម្រាប់ស្ត្រី និងសិក្ខាកាមដែលមានពិការភាព។
- **ជំនួយផ្នែកហិរញ្ញវត្ថុ៖** ឧបសគ្គផ្នែកហិរញ្ញវត្ថុធ្វើឱ្យមានវិសមភាពក្នុងការទទួលបានសេវាទឹកស្អាត និងអនាម័យកាន់តែធ្ងន់ធ្ងរ ជាពិសេសសម្រាប់គ្រួសារក្រីក្រ។ ការផ្ដល់គ្រឿងបរិក្ខារទឹកស្អាត និងអនាម័យ តាមរយៈការផ្ដល់ឧបត្ថម្ភធន អាចធ្វើឱ្យការចូលរួមច្រើន ជាពិសេសនៅក្នុងចំណោមប្រជាពលរដ្ឋដែលខ្វះខាត។ ការបញ្ចូលផែនការទឹកស្អាត និងអនាម័យ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ អាចធានាបាននូវហិរញ្ញប្បទានរយៈពេលវែង។ រាជរដ្ឋាភិបាលអាចផ្ដល់អាទិភាពដល់ហិរញ្ញប្បទាន សម្រាប់សហគមន៍ណាដែលបានបង្កើតផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ និងធ្វើផែនការសកម្មភាពច្បាស់លាស់។ វិធីសាស្ត្រផ្ដល់ហិរញ្ញប្បទានបែបនេះ មានប្រសិទ្ធភាពខ្ពស់នៅប្រទេសមួយចំនួន ដូចជា វ៉ាទូអាទូជាដើម។
- **កិច្ចសហការពីពហុភាគីពាក់ព័ន្ធ៖** ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងសហគមន៍។ តាមរយៈការប្រើប្រាស់ជំនាញ និងធនធានរួមគ្នា ភាគីពាក់ព័ន្ធទាំងនេះ អាចជំរុញសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុ និងប្រកបដោយបរិយាបន្ន។
- **ការកែលម្អទិន្នន័យអាកាសធាតុ និងការទទួលបានព័ត៌មាន៖** កង្វះទិន្នន័យអាកាសធាតុដែលអាចទុកចិត្ត ជា

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
cdri@cdri.org.kh
http://www.cdri.org.kh

ឧបសគ្គមួយសម្រាប់សហគមន៍ ក្នុងការវាយតម្លៃហានិភ័យអាកាសធាតុបានគ្រប់ជ្រុងជ្រោយ។ ការពង្រឹងការសម្របសម្រួលអន្តរក្រសួង (ឧ. រវាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម) អាចធ្វើឱ្យយន្តការចែករំលែកទិន្នន័យប្រសើរឡើង ដោយផ្តល់ការយល់ដឹងអំពីអាកាសធាតុនៅមូលដ្ឋាន ដល់អាជ្ញាធរឃុំសង្កាត់។ យុទ្ធសាស្ត្របន្ថែម ដូចជា ការបញ្ចូលទិន្នន័យឧតុនិយមជាមួយចំណេះដឹងជនជាតិដើម (ឧ. ការរំឮកអំពីទឹកជំនន់របស់មនុស្សចាស់ៗ) អាចជួយបំពេញកង្វះខាតផ្នែកទិន្នន័យអាកាសធាតុបាន។

- **ការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម៖** ដើម្បីបង្កើនប្រសិទ្ធភាពផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ គឺចាំបាច់ត្រូវពិចារណាបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គមជាប្រព័ន្ធនៅក្នុងដំណើរការធ្វើផែនការទាំងអស់។ នេះរួមមាន ការចាត់តាំងក្រុមការងារផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ដែលមានតុល្យភាពយេនឌ័រ ការផ្តល់កម្មវិធីកសាងសមត្ថភាពសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះ ការធានាឱ្យមានតំណាងរបស់ពួកគេក្នុងការសម្រេចចិត្ត និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលអាចប្រើប្រាស់បានគ្រប់គ្នា។
- **ការបង្ហាញពីគំរូជោគជ័យនៃផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ៖** រាជរដ្ឋាភិបាលគួរតែផ្សព្វផ្សាយពីគំរូជោគជ័យនៃផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុនានាដោយបង្ហាញឱ្យឃើញពីអត្ថប្រយោជន៍របស់វា ដូចជាភាពល្អប្រសើរនៃសុខភាពសាធារណៈ និងភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធជាដើម។ តាមរយៈការជំរុញកិច្ចសហការរវាងភាគីពាក់ព័ន្ធ និងការផ្តល់ការគាំទ្រដល់ការអនុវត្តផែនការ រាជរដ្ឋាភិបាលអាចនឹងលើកទឹកចិត្តឱ្យមានការទទួលយកគោលការណ៍ណែនាំទាំងនេះ កាន់តែទូលំទូលាយថែមទៀត។
- **ការត្រួតពិនិត្យ និងវាយតម្លៃ៖** កង្វះប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរឹងមាំ ធ្វើឱ្យគណនេយ្យភាពចុះខ្សោយ និងជាឧបសគ្គដល់ការសម្រេចចិត្តផ្នែកគោលនយោបាយទឹកស្អាត និងអនាម័យ ដោយផ្អែកលើភស្តុតាង។ ដើម្បីដោះស្រាយកង្វះខាតនេះ គួរតែមានក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃមួយ ដែលភ្ជាប់ទៅនឹងសកម្មភាពនានារបស់សហគមន៍នីមួយៗ នៅក្នុងផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ ដោយបញ្ចូលសូចនាករនានាទាក់ទងនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម។ ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃនេះ នឹងជួយតាមដានប្រសិទ្ធភាពនៃគោលការណ៍ណែនាំស្តីពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ និងការអនុវត្តផែនការ ដែលអំណោយផលដល់ការគ្រប់គ្រងផែនការដែលសមស្រប និងមានលទ្ធផលប្រកបដោយសមធម៌៕

## ឯកសារយោង

MISTI (Ministry of Industry, Science, Technology and Innovation). 2023. *Guideline for a Water Safety Plan Resilient to Climate Change for Clean Water Supply Services*. Phnom Penh: MISTI.

MRD (Ministry of Rural Development). 2023. *Guideline on Rural Water Safety Plan Resilient to Climate Change*. Phnom Penh: MRD.

NIS (National Institute of Statistics). 2024. *Report of Cambodia Socio-Economic Survey (CSES) 2023*. Phnom Penh: NIS

RGC (Royal Government of Cambodia). 2011. *National Strategy for Rural Water Supply, Sanitation and Hygiene 2011-2025*. Phnom Penh: RGC.

String, Gabrielle and Daniele Lantagne. 2016. "A systematic review of outcomes and lessons learned from general, rural, and country-specific Water Safety Plan implementations." *Water Supply* 16 (6): 1580–1594. https://doi.org/10.2166/ws.2016.073.

UNDP (United Nations Development Programme). 2022. *National Adaptation Plans in focus: Lessons from Cambodia*. New York: UNDP.

UNICEF (United Nations Children's Fund). 2024. *Climate rationale for water, sanitation and hygiene services in Cambodia*. https://www.unicef.org/cambodia/media/8731/file/Climate%20rationale_WASH_Cambodia_brief_ENG_2024.pdf.

WHO (World Health Organization). 2019. *A guide to equitable water safety planning: Ensuring no one is left behind*. Geneva: WHO.